# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

Ministry of Social Affairs, Veterans and Youth Rehabilitation

# ថវិកាសង្ខេប២០២៦

# BUDGET IN BRIEF

## ឆ្នាំ២០២៦




អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
**Building 788, Monivong Blvd, Sangkat Boeung Trabek, Khan Chamkamorn, Phnom Penh**

https://mosvy.gov.kh/ mosvycambodiaofficial @mosvycambodia mosvycambodia

# អារម្ភកថា

រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់, ឈ្លាសវៃ និង ប៉ិនប្រសប់ ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កំពុងបន្តជំរុញអនុវត្តកម្មវិធីនយោបាយ និងកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដោយមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការការពារអធិបតេយ្យជាតិ និងបូរណភាពទឹកដី ថែរក្សាសុខសន្តិភាព និងពន្លឿនការអភិវឌ្ឍសង្គម–សេដ្ឋកិច្ច ឆ្ពោះទៅសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។ ក្នុងបរិបទនេះ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ត្រូវបានរៀបចំឡើងដោយផ្តោតលើការតម្កល់មនុស្សជាអាទិភាព ការលើកកម្ពស់សមធម៌សង្គម និងការពង្រឹងប្រព័ន្ធគាំពារសង្គម ដើម្បីឆ្លើយតបនឹងសំណូមពរ និងក្តីប្រាថ្នារបស់ប្រជាជន។ ក្នុងន័យនេះ បេសកកម្មរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភាពស៊ីសង្វាក់យ៉ាងជិតស្និទ្ធជាមួយគោលដៅ និងគោលការណ៍សំខាន់ៗនៃថវិកាឆ្នាំ ២០២៦។ ជាក់ស្តែង ក្រសួងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០២៤–២០២៨ ដើម្បីអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ត្រង់មុំទី៤ នៃបញ្ចកោណទី១ ស្តីពី «ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង» ដែលមានគោលបំណងកសាង និងអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យមានលក្ខណៈប្រមូលផ្តុំ សង្គតិភាព និងគ្របដណ្តប់ប្រជាជនគ្រប់រូប ទាំងក្នុងប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។

បន្ថែមលើនេះ គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ២០២៦ ជាពិសេសការតម្កល់មនុស្សជាអាទិភាពទី១ ការរក្សាលំនឹងជីវភាពរស់នៅរបស់មន្ត្រីរាជការ និវត្តជន អតីតយុទ្ធជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ព្រមទាំងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំពារសង្គម សុទ្ធសឹងតែស្ថិតនៅក្នុងដែនបេសកកម្មស្នូលរបស់ក្រសួង។ ការផ្តល់អាទិភាពថវិកាសម្រាប់ការគាំពារ លើកកម្ពស់ និងស្តារជីវភាពរស់នៅរបស់ជនរងគ្រោះ និងជនងាយរងគ្រោះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពសង្គម កាត់បន្ថយភាពងាយរងហានិភ័យ និងបង្កើនភាពធន់រឹងមាំសង្គម ស្របតាមទិសដៅនៃថវិកាឆ្នាំ ២០២៦។

ការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ដោយមានការគាំទ្រពីថវិកាជាតិ និងដៃគូអភិវឌ្ឍន៍ នឹងជួយបំពេញគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ក្នុងការធានាសមធម៌សង្គម ការពារជីវភាពប្រជាជន និងគាំទ្រការអភិវឌ្ឍសង្គម–សេដ្ឋកិច្ចប្រកបដោយចីរភាព។

ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ និងសប្បុរសជនទាំងអស់ ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ និងបានរួមចំណែកបង្កើតវឌ្ឍនភាពគួរជាទីមោទនៈ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងអង្គការដៃគូពាក់ព័ន្ធទាំងអស់ នឹងបន្តរួមសហការគ្នាអនុវត្តផែនការសកម្មភាពឆ្នាំ២០២៦នេះ ឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់បន្ថែមទៀត។

ថ្ងៃចន្ទ ១០ កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ជា សុមេធី**

# មាតិកា


១. សេចក្ដីផ្ដើម ....................................................................................... ១
១.១.គោលបំណងនៃថវិកាសង្ខេបរបស់ក្រសួង ស.អ.យ. ................................................. ១
១.២.បេសកកម្ម និងភារកិច្ចចម្បងៗរបស់ក្រសួង ស.អ.យ. ................................................. ២
១.២.១.បេសកកម្ម និងភារកិច្ច.......................................................................... ២
១.២.២.សេវាសាធារណៈ ..................................................................................... ៣
*ក.សេវាសង្គមកិច្ច* ..................................................................................... ៣
*ខ. សេវាស្ដារសម្បទា* ................................................................................... ៣
*គ.ប្រព័ន្ធគាំពារសង្គម* ................................................................................ ៣
២. រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ស.អ.យ ......................................................... ៤
២.១.ការរៀបចំកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព.................................................. ៤
២.២.គោលបំណងកម្មវិធី................................................................................. ៥
៣. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥................................................................. ៥
កម្មវិធីទី១÷ លើកកម្ពស់សេវាសង្គមកិច្ច............................................................... ៥
*១.១ ការលើកកម្ពស់សេវាគាំពារមនុស្សចាស់ និងអតីតយុទ្ធជន* ....................................... ៥
*១.២ ការលើកកម្ពស់សេវាកិច្ចការពារកុមារ* ........................................................... ៦
*១.៣. លើកកម្ពស់ការតាមដានការអនុវត្តសិទ្ធិកុមារ* ................................................... ៧
*១.៤. លើកកម្ពស់កិច្ចការគ្រួសារ* ........................................................................ ៧
*១.៥. លើកកម្ពស់សេវាគាំពារជនរងគ្រោះ* ............................................................... ៨
*១.៥.១. ការងារសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ និងងាយរងគ្រោះ* ....................................... ៨
*១.៥.២. ការងារជនអនាថា និងអ្នកផ្ទុកមេរោគអេដស៍*..................................................... ៨
*១.៥.៣. ការគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ* ........................ ៨
កម្មវិធីទី២÷ ការគ្រប់គ្រងសេវាស្ដារជនរងគ្រោះ......................................................... ៩
*២.១. លើកកម្ពស់សេវាស្ដារនីតិសម្បទាអនីតិជន*.......................................................... ៩
*២.២. លើកកម្ពស់សេវាស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន*............................................. ៩
*២.៣. លើកកម្ពស់សុខុមាលភាពជនមានពិការភាព*......................................................... ៩
*២.៤. លើកកម្ពស់ការតាមដានការអនុវត្តសិទ្ធិជនពិការ* ................................................ *10*
*២.៥. កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច*............................................................ ១០
*២.៦.លើកកម្ពស់សេវាស្ដារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាព* ........................... ១០
*២.៦.១.ការផ្ដល់សេវាស្ដារលទ្ធភាពពលកម្មកាយសម្បទា* .................................................. ១១
*២.៦.២. សេវាស្ដារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ* ............................................................ ១១

**កម្មវិធីទី៣៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម ........................................ ១១**
*៣.១.ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ........................................ ១១*
*៣.២.ការបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ........................................ ១២*
*៣.៣.ការបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ ........................................ ១២*
**កម្មវិធីទី៤៖ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច ........................................ ១៣**
*៤.១. លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ........................................ ១៣*
*៤.១.១.ការងាររដ្ឋបាល និងបុគ្គលិក ........................................ ១៣*
*១.២.ការងារផែនការ ស្ថិតិ និងសរុប ........................................ ១៣*
*១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ ........................................ ១៣*
*១.៤.ការងារសហប្រតិបត្តិការ ........................................ ១៤*
*១.៥.ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ........................................ ១៤*
*១.៦.ការងារគោលនយោបាយសង្គមកិច្ច ........................................ ១៥*
*២.អភិវឌ្ឍធនធានមនុស្សវិស័យសង្គមកិច្ច ........................................ ១៥*
**៤. ថវិកាក្រសួង ស.អ.យ. ប្រចាំឆ្នាំ ២០២៦ ........................................ ១៦**
*៤.១.ធនធានថវិកាឆ្នាំ ២០២៦ ........................................ ១៦*
**៥.សេចក្តីសន្និដ្ឋាន ........................................ ២២**

## បញ្ជីតារាង

តារាងទី១.តារាងសង្ខេបចំនួនកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ........................................ ៤
តារាងទី២.ក្រាហ្វិកថវិការក្រសួងតាមកម្មវិធី ........................................ ១៦
តារាងទី៣.គម្រោងថវិកាចំណាយតាមកម្មវិធី និងអនុកម្មវិធី ........................................ ១៧
តារាងទី៤.ក្រាហ្វិកថវិកាកម្មវិធីទី១ លើកកម្ពស់សេវាសង្គមកិច្ច ........................................ ១៨
តារាងទី៥.ក្រាហ្វិកថវិកាកម្មវិធីទី២ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ ........................................ ១៨
តារាងទី៦.ក្រាហ្វិកថវិកាកម្មវិធីទី៣ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម (មជជ) ........................................ ១៩
តារាងទី៧.ក្រាហ្វិកថវិកាកម្មវិធីទី៤ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច ........................................ ២០

# ១. សេចក្តីផ្តើម

## ១.១.គោលបំណងនៃថវិកាសង្ខេបរបស់ក្រសួង ស.អ.យ.

ថវិកាសង្ខេបប្រចាំឆ្នាំរបស់ក្រសួងស.អ.យ. មានតួនាទីសំខាន់ក្នុងការគាំទ្រការអនុវត្តគោលនយោបាយសង្គម និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនរងគ្រោះ ងាយរងគ្រោះ អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល ជនមានពិការភាព កុមារ និងយុវជនដែលត្រូវការស្តារនីតិសម្បទា។ ការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព និងតម្លាភាព និងធានាឲ្យមានការបែងចែកធនធានស្របតាមអាទិភាព និងតម្រូវការជាក់ស្តែងរបស់សង្គម។

ថវិការបស់ក្រសួងផ្តោតលើកម្មវិធីសំខាន់ៗរួមមាន ការផ្តល់សេវាគាំពារសង្គមដល់ជនក្រីក្រ និងជនងាយរងគ្រោះ ការឧបត្ថម្ភ និងថែទាំអតីតយុទ្ធជន ការផ្តល់សេវាស្តារនីតិសម្បទាដល់ជនមានពិការភាព និងកុមារ ដោយអនុវត្តកម្មវិធីចំនួន៤ រួមមានជាអាថ៌ ការលើកកម្ពស់សេវាសង្គមកិច្ច ,ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ ,សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម និងសេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច។ ការបែងចែកថវិកាទៅលើវិស័យទាំងនេះ មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់សមធម៌សង្គម។

ដើម្បីពង្រឹងការគ្រប់គ្រងថវិកា ក្រសួងគួរបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាព តាមរយៈការបង្ហាញព័ត៌មានថវិកា និងលទ្ធផលអនុវត្តឲ្យបានច្បាស់លាស់។ ជាមួយគ្នានេះការរៀបចំថវិកាផ្អែកលើលទ្ធផល ដោយភ្ជាប់ថវិកាជាមួយសូចនាករអនុវត្ត ដូចជា ចំនួនអ្នកទទួលផលពីកម្មវិធីគាំពារសង្គម ចំនួនអតីតយុទ្ធជនទទួលបានសេវាឧបត្ថម្ភ និងចំនួនកុមារឬយុវជនទទួលបានសេវាស្តារនីតិសម្បទា។ វិធីសាស្ត្រនេះនិងជួយវាស់វែងប្រសិទ្ធភាពនៃការចំណាយ និងធានាថាថវិកាត្រូវបានប្រើប្រាស់ស្របតាមគោលបំណង។ បន្ថែមពីនេះ ក្រសួងបានផ្តល់អាទិភាពលើការពង្រឹងគុណភាពសេវាសង្គម ពង្រីកការអនុវត្តកម្មវិធីគាំពារសង្គមដល់តំបន់ដាច់ស្រយាល និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ។ ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រងទិន្នន័យអ្នកទទួលផល និងការគ្រប់គ្រងថវិកាក៏អាចជួយកាត់បន្ថយកំហុស និងបង្កើនប្រសិទ្ធភាពការងារ។ ទន្ទឹមនឹងនេះ ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងនឹងជួយធានាបាននូវការអនុវត្តថវិកាប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព។

សរុបមក ថវិកាសង្ខេបប្រចាំឆ្នាំក្រសួងស.អ.យ. គឺជាឧបករណ៍ដ៏សំខាន់សម្រាប់គាំទ្រការអនុវត្តគោលនយោបាយសង្គម និងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ។ ការគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងផ្អែកលើលទ្ធផល នឹងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងប្រព័ន្ធការពារសង្គម និងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ដោយមានគោលបំណងលើកកម្ពស់ភាពថ្លៃថ្នូរ ភាពបើកចំហ និងការយល់ដឹងរបស់សាធារណៈជន ព្រមទាំងពង្រឹងទំនាក់ទំនង និងការចូលរួមរវាងក្រសួង និងប្រជាពលរដ្ឋទូទៅ។

ថវិកាប្រចាំឆ្នាំរបស់ក្រសួងស.អ.យ. មានតួនាទីសំខាន់ក្នុងការគាំទ្រការអនុវត្តគោលនយោបាយសង្គម និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ជាពិសេសចំពោះក្រុមជនរងគ្រោះ និងងាយរងគ្រោះ អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល ជនមានពិការភាព កុមារ និងយុវជន ដែលត្រូវការការស្តារនីតិសម្បទា។ ការរៀបចំថវិកាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព និងធានាឱ្យការបែងចែកធនធានមានភាពសមស្រប ស្របតាមអាទិភាព និងតម្រូវការជាក់ស្តែងរបស់សង្គម។

ថវិការបស់ក្រសួងផ្តោតលើការអនុវត្តកម្មវិធីសំខាន់ៗ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពសង្គម និងពង្រឹងប្រព័ន្ធការពារសង្គម។ ក្នុងនោះ ក្រសួងបានអនុវត្តកម្មវិធីចំនួន ៤ រួមមាន៖ ការលើកកម្ពស់សេវាសង្គមកិច្ច ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម និងសេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច។ កម្មវិធីទាំងនេះរួមចំណែកដល់ការផ្តល់សេវាគាំពារសង្គមដល់ជនក្រីក្រ និងជនងាយរងគ្រោះ ការឧបត្ថម្ភ និងថែទាំអតីតយុទ្ធជន ព្រមទាំងការផ្តល់សេវាស្តារនីតិសម្បទាដល់ជនមានពិការភាព និងកុមារ។

ការបែងចែកថវិកាទៅលើវិស័យទាំងនេះ មានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងលើកកម្ពស់សមធម៌សង្គម។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងថវិកា ក្រសួងគួរបន្តលើកកម្ពស់តម្លាភាព និងគណនេយ្យភាព តាមរយៈការបង្ហាញព័ត៌មានថវិកា និងលទ្ធផលអនុវត្តឱ្យបានច្បាស់លាស់។ ទន្ទឹមនឹងនេះ ការរៀបចំថវិកាផ្អែកលើលទ្ធផលត្រូវបានអនុវត្តដោយភ្ជាប់ថវិកាជាមួយសូចនាករអនុវត្ត ដូចជា ចំនួនអ្នកទទួលផលពីកម្មវិធីគាំពារសង្គម ចំនួនអតីតយុទ្ធជននិងនិវត្តជនទទួលបានសេវាឧបត្ថម្ភ និងចំនួនកុមារ ឬយុវជនទទួលបានសេវាស្តារនីតិសម្បទា។ វិធីសាស្រ្តនេះនឹងជួយវាស់វែងប្រសិទ្ធភាពនៃការចំណាយ និងធានាថាថវិកាត្រូវបានប្រើប្រាស់ស្របតាមគោលបំណង។

បន្ថែមពីនេះ ក្រសួងបានផ្តល់អាទិភាពលើការពង្រឹងគុណភាពសេវាសង្គម ការពង្រីកការអនុវត្តកម្មវិធីគាំពារសង្គមដល់តំបន់ដាច់ស្រយាល និងការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញ។ ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការគ្រប់គ្រងទិន្នន័យអ្នកទទួលផល និងការគ្រប់គ្រងថវិកា អាចជួយកាត់បន្ថយកំហុស និងបង្កើនប្រសិទ្ធភាពការងារ។ ទន្ទឹមនឹងនេះ ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង នឹងជួយធានាថាការអនុវត្តថវិកាប្រព្រឹត្តទៅដោយត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

សរុបមក ថវិកាសង្ខេបប្រចាំឆ្នាំរបស់ក្រសួងស.អ.យ. គឺជាឧបករណ៍ដ៏សំខាន់សម្រាប់គាំទ្រការអនុវត្តគោលនយោបាយសង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ។ ការគ្រប់គ្រងថវិកាប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងផ្អែកលើលទ្ធផល នឹងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រឹងប្រព័ន្ធការពារសង្គម និងការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ស្របតាមគោលបំណងលើកកម្ពស់ភាពថ្លៃថ្នូរ ភាពបើកចំហ និងការយល់ដឹងរបស់សាធារណៈជន ព្រមទាំងពង្រឹងទំនាក់ទំនង និងការចូលរួមរវាងក្រសួង និងប្រជាពលរដ្ឋ។

## ១.២.បេសកកម្ម និងភារកិច្ចចម្បងៗរបស់ក្រសួង ស.អ.យ.

### ១.២.១.បេសកកម្ម និងភារកិច្ច

ក្រសួង ស.អ.យ. បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួង ស.អ.យ. មានមុខងារ និងភារកិច្ចដូចខាងក្រោម៖

- ការរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្រ្ត ទិសដៅ និងផែនការរួមរបស់រាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំគោលនយោបាយផែនការយុទ្ធសាស្រ្ត ផែនការសកម្មភាពគោលដៅទិសដៅកម្មវិធី យន្តការក្នុងការគ្រប់គ្រងដឹកនាំ ចាត់ចែង ផ្តល់សេវាគាំពារដល់មុខសញ្ញាក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- កសាង និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងផែនការពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របតាមលិខិតបទដ្ឋានជាតិ និងអន្តរជាតិ
- សិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រលើផ្នែកសង្គមកិច្ច
- គ្រប់គ្រងការងារសុំកូនក្នុងប្រទេស និងអន្តរប្រទេស
- ដឹកនាំ គ្រប់គ្រង និងសហការជាមួយដៃគូ អង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- រៀបចំបង្កើតយន្តការជំរុញបំផុសការចូលរួមសកម្មភាពក្នុងការងារសង្គមកិច្ច សាមគ្គីធម៌សង្គម លើកទឹកចិត្តដល់ក្រុមហ៊ុន សហគ្រាសរដ្ឋ ឯកជន អង្គការមនុស្សធម៌ ដៃគូអភិវឌ្ឍ សហគមន៍ និងមហាជនដែលបានចូលរួមសកម្មភាពដើម្បីសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ១.២.២.សេវាសាធារណៈ

ក្រសួង ស.អ.យ. បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំ និងគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងទទួលខុសត្រូវផ្តល់សេវាសាធារណៈចម្បងៗដែលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តិមានដូចខាងក្រោម៖

### ក.សេវាសង្គមកិច្ច

- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀងទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍
- ផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍
- ដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា
- ផ្តល់សេវាថែទាំ ព្យាបាល និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី
- មាតុភូមិនិវត្ត ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន
- ថែទាំជំនួសចំពោះកុមារ
- សុំកូនក្នុងប្រទេស
- សុំកូនអន្តរប្រទេស
- បណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ
- អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនមានពិការភាព



### ខ. សេវាស្តារសម្បទា

- ស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ
- ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- ស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់
- កម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់
- ស្តារលទ្ធភាពពលកម្មកាយសម្បទា និងវេជ្ជសាស្ត្រជូនជនមានពិការភាព



### គ.ប្រព័ន្ធគាំពារសង្គម

ប្រព័ន្ធគាំពារសង្គមនៅកម្ពុជា គឺជាយន្តការមួយដែលរាជរដ្ឋាភិបាលបង្កើតឡើង ដើម្បីជួយកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សុខុមាលភាព និងការពារពលរដ្ឋពីហានិភ័យផ្សេងៗ ដូចជា ជំងឺ គ្រោះថ្នាក់ការងារ ឬភាពចាស់ជរា។ មូលនិធិជាតិជំនួយសង្គម(ម.ជ.ជ) អនុវត្តប្រព័ន្ធគាំពារសង្គម មានសសរស្តម្ភចំនួនពីរ ៖

១. ប្រព័ន្ធជំនួយសង្គម (Social Assistance)

ផ្នែកនេះផ្តោតលើការជួយជនក្រីក្រ និងជនងាយរងគ្រោះ ដែលមិនមានលទ្ធភាពបង់ភាគទាន។ រដ្ឋជាអ្នកចេញថវិកាទាំងស្រុង, អនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារតាមរយៈ



- ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ
- ការឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព
- ការឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា(អាយុ៦០ឆ្នាំឡើង) និងការរួមបញ្ចូលការឧបត្ថម្ភគោលសម្រាប់គ្រួសារនិង




ឧបត្ថម្ភសមាជិកគ្រួសារអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅក្នុងអំឡុងខែមេសា ឆ្នាំ២០២៤។

- ការផ្ទេរសាច់ប្រាក់ ដូចជា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ, កម្មវិធីជួយគ្រួសារក្រីក្រក្នុងអំឡុងពេលកូវីដ-១៩ ឬ គ្រោះទឹកជំនន់។
- របបសន្តិសុខស្បៀង កម្មវិធីផ្តល់អាហារតាមសាលារៀន។
- អាហារូបករណ៍ ការជួយកុមារមកពីគ្រួសារក្រីក្រឱ្យបានរៀនសូត្រ។

២. សន្តិសុខសង្គម (Social Security)

- បើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈនិងអ្នកនៅក្នុងបន្ទុក
- បើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន។

## ២. រចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ស.អ.យ

### ២.១.ការរៀបចំកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព

ដើម្បីសម្រេចឱ្យបានគោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ស.អ.យ. ២០២៤-២០២៨ ខាងលើ ទទួលបានជោគជ័យប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងឆ្នាំ២០២៦ ក្រសួង ស.អ.យ. ដាក់ចេញនូវកម្មវិធីចំនួន៤ អនុកម្មវិធីចំនួន២១ និងចង្កោមសកម្មភាពចំនួន៨២[៧]។

តារាងទី១.តារាងសង្ខេបចំនួនកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព

| ឈ្មោះកម្មវិធី | អនុកម្មវិធី | ចង្កោមសកម្មភាព |
|---|---|---|
| កម្មវិធីទី១៖ លើកកម្ពស់សេវាសង្គមកិច្ច | ៥ | ១៩ |
| កម្មវិធីទី២៖ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ | ៦ | ២១ |
| កម្មវិធីទី៣៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម | ៤ | ១៤ |
| កម្មវិធីទី៤៖ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច | ៦ | ២០ |

[៧] *ផែនការសកម្មភាពអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ២០២៥*

## ២.២.គោលបំណងកម្មវិធី




## ៣. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥

### កម្មវិធីទី១៖ លើកកម្ពស់សេវាសង្គមកិច្ច

### ១.១ ការលើកកម្ពស់សេវាគាំពារមនុស្សចាស់ និងអតីតយុទ្ធជន

ក្នុងការលើកកម្ពស់សេវាគាំពារសម្រាប់មនុស្សចាស់ និងអតីតយុទ្ធជន ក្រសួងបានអនុវត្តសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- បានផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីគុណតម្លៃរបស់មនុស្សវ័យចាស់ទៅកាន់សាធារណជន តាមរយៈការប្រារព្ធខួបលើកទី២៧ នៃទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៥ ទាំងនៅថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ក្រោមប្រធានបទ «វ័យចាស់ដោយសេចក្ដីថ្លៃថ្នូរ» ដែលមានអ្នកចូលរួមសរុបចំនួន ១,៧៨២ នាក់។
- បានរៀបចំសិក្ខាសាលាស្ដីពីការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង ដើម្បីឈានចូលវ័យចាស់ មានអ្នកចូលរួមចំនួន ១០០ នាក់ ស្មើនឹង ១០០% នៃផែនការ។
- បានរៀបចំសេចក្ដីព្រាងទី១ នៃសៀវភៅបណ្ដុះបណ្ដាលជំនាញថែទាំមនុស្សវ័យចាស់ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមនុស្សចាស់ សម្រាប់អំឡុងឆ្នាំ២០២៥-២០២៩។
- បានរៀបចំរបាយការណ៍វឌ្ឍនភាពរយៈពេល ៣ ឆ្នាំ នៃការអនុវត្តផែនការសកម្មភាព (២០២១-២០២៥) នៃគោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ (២០១៧-២០៣០) ព្រមទាំងសេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីការបង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់អន្តរជំនាន់ និងពហុមុខងារ។ ជាមួយគ្នានេះក៏បានជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធចំនួន ៣០ ឲ្យបង្កើតក្រុមការងារមនុស្សចាស់ផងដែរ។
- សមាគមមនុស្សចាស់ទូទាំងប្រទេសមានចំនួនសរុប ១,៦៤៦ សមាគម ក្នុងនោះដំណើរការបាន ៥៣៣ សមាគម ខណៈ ១,១១៣ សមាគមកំពុងបន្តពង្រឹង និងទទួលការគាំទ្រផ្នែកបច្ចេកទេស។ ក្រសួងក៏បាន

រៀបចំកិច្ចប្រជុំ និងសិក្ខាសាលា ដើម្បីពង្រឹងសមាគមមនុស្សចាស់នៅតាមឃុំ-សង្កាត់ ក្នុងខេត្តព្រះសីហនុ កែប កំពត បាត់ដំបង តាកែវ កំពង់ស្ពឺ ស្វាយរៀង និងសៀមរាប។

- ដើម្បីលើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អតីតយុទ្ធជន និងនិវត្តជន រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ស្តីពីទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា។ ក្រសួងបានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា រៀបចំប្រារព្ធទិវាអតីតយុទ្ធជន ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី។ មន្ទីររាជធានី-ខេត្តក៏បានចូលរួមប្រារព្ធផងដែរ។
- សមាជិកសមាគមអតីតយុទ្ធជនកម្ពុជា មានចំនួនសរុប ៨៨,៧៣៤ នាក់ ហើយបានសាងសង់ផ្ទះជូនចំនួន ១,០៣៣ ខ្នង។ សមាគមទទួលបានថវិកាឧបត្ថម្ភពីរដ្ឋចំនួន ៨,០០០ លានរៀល។ នៅក្នុងមហាសន្និបាតថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ បានសម្រេចប្តូរឈ្មោះទៅជា «សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា» និងបន្ថែមសមាជិកជាអតីតមន្ត្រីរាជការ។ ក៏ដូចជាការកំណត់ថវិកាឧបត្ថម្ភប្រចាំឆ្នាំចំនួន ៨,០០០ លានរៀល ចាប់ពីឆ្នាំ២០២៦ និងគម្រោងសាងសង់ផ្ទះ ១០០ ខ្នងក្នុងមួយឆ្នាំ រយៈពេល ៥ ឆ្នាំ (២០២៦-២០៣០)។

## ១.២ ការលើកកម្ពស់សេវាកិច្ចការពារកុមារ

ក្នុងវិស័យការពារកុមារ ក្រសួងបានអនុវត្តនូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

- គោលនយោបាយថែទាំជំនួសសម្រាប់កុមារ និងបទដ្ឋានអប្បបរមា ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។ មានកន្លែងថែទាំកុមារសរុប ២៤០ កន្លែង ដែលផ្តល់សេវាជូនកុមារ និងយុវជនសរុប ៩,២៥១ នាក់ (ស្រី ៥,០៣៦ នាក់) ក្នុងនោះ កុមារអាយុក្រោម ១៨ ឆ្នាំមានចំនួន ៧,៣៦១ នាក់ (ស្រី ៤,០២៩ នាក់)។ បើប្រៀបធៀបនឹងឆ្នាំ២០២៤ ចំនួនកន្លែងថែទាំថយចុះ ៦% ប៉ុន្តែចំនួនកុមារកើនឡើង ៥% (ស្មើនឹង ៣៦០ នាក់)។
- គោលនយោបាយថែទាំជំនួស និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារ ត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន។ មានមណ្ឌលថែទាំកុមារសរុប ២៤០កន្លែង មានកុមារ និងយុវជនសរុប ៩,២៥១នាក់ ក្នុងនោះកុមារ ០-១៧ឆ្នាំ មាន ៧,៣៦១នាក់។ បើប្រៀបធៀបឆ្នាំ២០២៤ ចំនួនមណ្ឌលថយចុះ ៦% ប៉ុន្តែកុមារកើនឡើង ៥%។
- មណ្ឌលរដ្ឋមាន ២១កន្លែង មានកុមារ និងយុវជនសរុប ១,០៧៧នាក់ កើនឡើងប្រមាណ ១.០៨%។
- កុមារទទួលបានសេវាថែទាំជំនួសក្នុងគ្រួសារផ្លូវការចំនួន ៨៨៦នាក់ កើនឡើង ៥៥% ប្រៀបធៀបឆ្នាំមុន។
- កុមារដែលត្រូវបានបង្រួបបង្រួមគ្រួសារ ឬចាកចេញពីមណ្ឌល មានសរុប ៧៦៦នាក់ និងយុវជន ២២០នាក់ កើនឡើង ១៤១%។
- ករណីកិច្ចការពារកុមារដែលត្រូវបានគ្រប់គ្រងមានចំនួន ១,៧៣៤ករណី ថយចុះ ៥២% ប្រៀបធៀបផែនការ។
- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារ សម្រេចបាន ៧០% និងមានគោលបំណងធានាសិទ្ធិ ការថែទាំ និងការចូលរួមរបស់កុមារ ព្រមទាំងពង្រឹងការទទួលខុសត្រូវរបស់មាតាបិតា និងអាណាព្យាបាល។
- ក្រសួងបានអនុវត្តយុទ្ធនាការ «គ្រួសាររឹងមាំ» ដើម្បីទប់ស្កាត់អំពើហិង្សាលើកុមារតាមរយៈការផ្សព្វផ្សាយតាមបណ្តាញសង្គម ៥៦ដង ដល់ប្រជាជនជាង ១.៣លាននាក់។
- បានបណ្តុះបណ្តាលឃុំ-សង្កាត់ចំនួន ១១៦ អំពីការការពារកុមារ លើសផែនការ និងរៀបចំសិក្ខាសាលាថ្នាក់ជាតិពាក់ព័ន្ធនឹងសិទ្ធិកុមារ។

- បានពង្រឹងនីតិវិធីសុំកូនក្នុងប្រទេស តាមរយៈការបណ្តុះបណ្តាល និងការត្រួតពិនិត្យតាមដាន។ ជាលទ្ធផល មានករណីសម្រេចសុំកូន ២០ករណី កើនឡើងយ៉ាងខ្លាំង។
- បានបណ្តុះបណ្តាលអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៥ និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារ ៦៥មណ្ឌល។
- បានចូលរួមកិច្ចប្រជុំអន្តរជាតិ និងពិភាក្សាលើកិច្ចសហប្រតិបត្តិការការពារកុមារជាមួយប្រទេសថៃ ទោះបីដំណើរការចុះអនុស្សរណៈត្រូវបានផ្អាកជាបណ្តោះអាសន្នក៏ដោយ។
- បានបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលក្នុងខេត្ត និងក្រុង-ស្រុក ព្រមទាំងបញ្ចូលទិន្នន័យសុំកូនអន្តរប្រទេសចំនួន ៤៩៧ករណី និងតាមដានកុមារសុំ ៩៤ករណី។
- បានត្រួតពិនិត្យទីភ្នាក់ងារសុំកូនអន្តរប្រទេស ២កន្លែង និងកំណត់កុមារសមស្របសម្រាប់សុំកូនអន្តរប្រទេស ៥នាក់។
- បានរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាពង្រឹងសមត្ថភាពលើនីតិវិធីសុំកូនទាំងក្នុង និងក្រៅប្រទេស។

## ១.៣. លើកកម្ពស់ការតាមដានការអនុវត្តសិទ្ធិកុមារ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានសហការជាមួយអង្គការ និងដៃគូអភិវឌ្ឍ ដើម្បីអនុវត្តសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- បានផ្សព្វផ្សាយ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ ឆ្នាំ២០២៥-២០៣០ នៅទីស្តីការក្រសួង។
- បានអនុវត្តការវាយតម្លៃពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាពស្តីពីការបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (២០២១-២០២៥) និងរៀបចំរបាយការណ៍ស្ថានភាពកុមារ ឆ្នាំ២០២៥ ជាមួយទិសដៅអនុវត្តបន្ត។
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងសិក្ខាសាលាថ្នាក់តំបន់ស្តីពីសិទ្ធិកុមារ និងការការពារកុមារតាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមសរុប ១៦២នាក់ ព្រមទាំងសាកល្បងកម្មវិធីស្វ័យសិក្សាតាមទូរស័ព្ទស្តីពីសុវត្ថិភាពអនឡាញ នៅខេត្តបាត់ដំបង ព្រៃវែង និងក្រចេះ។
- បានផ្សព្វផ្សាយការយល់ដឹងអំពីអនុសញ្ញាសិទ្ធិកុមារ និងបទដ្ឋានពាក់ព័ន្ធ តាមរយៈសិក្ខាសាលា វេទិកាកុមារ កម្មវិធីតុមូលតាមទូរទស្សន៍ និងការប្រារព្ធទិវាសំខាន់ៗ រួមមាន ទិវាកុមារអន្តរជាតិ ១មិថុនា ទិវាកុមារកម្ពុជា ឆ្នាំ២០២៥ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ដែលមានអ្នកចូលរួមសរុប ១,៨៣៦នាក់។

## ១.៤. លើកកម្ពស់កិច្ចការគ្រួសារ

ក្រសួងបានអនុវត្តសកម្មភាពដើម្បីលើកកម្ពស់សុខមាលភាពគ្រួសារ ដូចខាងក្រោម៖

- បានរៀបចំពិធីសំណេះសំណាល និងចែកអំណោយជូនមនុស្សវ័យចាស់ចំនួន ៣០០នាក់ ក្នុងឱកាសទិវាក្តីស្រឡាញ់ (១៤ កុម្ភៈ ២០២៥) នៅរាជធានីភ្នំពេញ និងបានជួយប្រជាជននៅតំបន់ទីលានចាក់សំរាមខណ្ឌដង្កោចំនួន ៤៦៩គ្រួសារ។
- បានប្រារព្ធទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៥ (ខួបទី១១៤) និងទិវាគ្រួសារ ១៥ ឧសភា ឆ្នាំ២០២៥ (ខួបទី៣១) ដោយមានអ្នកចូលរួមសរុបរាប់រយនាក់ និងបានផ្តល់ការឧបត្ថម្ភដល់មន្ត្រីស្ត្រីចំនួន ៨២៥នាក់។

- បានគាំទ្រផ្នែកសេដ្ឋកិច្ចដល់គ្រួសារគោលដៅ ២១០គ្រួសារ នៅក្រុងបាត់ដំបង និងបានរៀបចំសៀវភៅណែនាំស្តីពីការពង្រឹងភាពធន់សេដ្ឋកិច្ចគ្រួសាររងគ្រោះ ព្រមទាំងបណ្តុះបណ្តាលគ្រូបង្គោល និងគ្រួសារក្រីក្រអំពីការគ្រប់គ្រងហិរញ្ញវត្ថុ។
- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៨វគ្គ (អ្នកចូលរួម ២៧០នាក់) ស្តីពីសមភាពយេនឌ័រ ប្រព័ន្ធគាំពារសង្គម និងការបញ្ជ្រាបយេនឌ័រ ព្រមទាំងបណ្តុះបណ្តាលអប់រំសុខភាពផ្លូវចិត្តដល់មន្ត្រី និងអ្នកថែទាំ។

## ១.៥. លើកកម្ពស់សេវាគាំពារជនរងគ្រោះ

### ១.៥.១. ការងារសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ និងងាយរងគ្រោះ

- ក្រសួងបានអន្តរាគមន៍ជួយពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ដោយផ្តល់ស្បៀងអាហារ និងមធ្យោបាយដឹកជញ្ជូនត្រឡប់ទៅសហគមន៍ ព្រមទាំងសហការជាមួយអាជ្ញាធរ និងអង្គការដៃគូ ដើម្បីគ្រប់គ្រងស្ថានការណ៍ និងផ្តល់ការគាំទ្រផ្លូវចិត្ត។
- ចំពោះប្រជាពលរដ្ឋភៀសសឹក ក្រសួងបានផ្តល់ស្បៀងអាហារ សម្ភារៈចាំបាច់ និងសេវាពិគ្រោះយោបល់ផ្លូវចិត្ត ព្រមទាំងរៀបចំកម្មវិធីសម្រាប់កុមារ និងជនងាយរងគ្រោះនៅតំបន់សុវត្ថិភាព។
- គ្រួសាររងគ្រោះដោយភាពក្រីក្រ គ្រោះធម្មជាតិ និងមហន្តរាយទទួលបានជំនួយសង្គ្រោះបន្ទាន់ចំនួន ៥០,១៧១គ្រួសារ (សម្រេចបាន ៩១.២%) និងកើនឡើង ៤៤% ប្រៀបធៀបឆ្នាំ២០២៤។

### ១.៥.២. ការងារជនអនាថា និងអ្នកផ្ទុកមេរោគអេដស៍

- បានផ្តល់សេវាពិគ្រោះយោបល់ និងការពារជនអនាថាចំនួន ១,១៤៥នាក់ និងជំរុញឱ្យរដ្ឋបាលមូលដ្ឋានបញ្ចូលការងារនេះក្នុងផែនការ។ ជនអនាថាចំនួន ៤៨០នាក់ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- បានធ្វើសមាហរណកម្មជនអនាថាទៅគ្រួសារនិងសហគមន៍វិញចំនួន១,១៤៥នាក់ (សម្រេចបាន ២១២%)។
- បានសហការរៀបចំគោលនយោបាយស្តីពីការគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថា(២០២៥-២០៣៥)។
- បានផ្តល់សេវាគាំទ្រដល់ជនរងផលប៉ះពាល់ដោយមេរោគអេដស៍ និងជំងឺធ្ងន់ធ្ងរ ចំនួន ២៥០នាក់ (សម្រេចបាន ២៥០%)។
- មជ្ឈមណ្ឌលជនវិបល្លាសស្មារតី បានទទួលអ្នកជំងឺថ្មី ១២៩នាក់ និងធ្វើសមាហរណកម្មវិញ ៦៦នាក់។

### ១.៥.៣. ការគាំពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរំលោភបំពានផ្លូវភេទ

- ជនរងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសដើមមានចំនួន ២៨នាក់ ខណៈជនរងគ្រោះពីក្រៅប្រទេសមាន ២៦៤នាក់ (កើនឡើង ២៧%)។
- បានទទួល និងបញ្ជូនជនរងគ្រោះទៅស្ថាននីតិសម្បទា សរុប ៣៥៥នាក់ និងធ្វើសមាហរណកម្មទៅគ្រួសារនិងសហគមន៍វិញ ២០០នាក់។
- បានតាមដានក្រោយសមាហរណកម្មចំនួន ៤៣៦នាក់ និងបិទករណី ១០៧នាក់។
- បានទទួលជនរងគ្រោះពីប្រទេសថៃចំនួន ៧,៩៩០នាក់ និងជនងាយរងគ្រោះស្នាក់នៅមណ្ឌលសំចតចំនួន ២,០៥៤នាក់។

## កម្មវិធីទី២៖ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ

### ២.១. លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យអនីតិជនទំនាស់នឹងច្បាប់នៅពន្ធនាគារ មណ្ឌលអប់រំកែប្រែ និងមណ្ឌលឃុំនីតិសម្បទាទូទាំងរាជធានី-ខេត្ត សរុប ៤,៤០៨នាក់ (ស្រី ១៥៧នាក់) ក្នុងនោះ ទណ្ឌិត ១,១៩៥នាក់ និងពិរុទ្ធជន ៣,២១៣នាក់។
- មណ្ឌលឃុំនីតិសម្បទាបានទទួលអនីតិជនសរុប ៩២៣នាក់ (១៥៤% នៃផែនការ) និងបានសមាហរណកម្ម ៣៣១នាក់ (១៥៣%)។ បច្ចុប្បន្នមានអនីតិជនស្នាក់នៅ ៥៩២នាក់។
- អនីតិជនជាទណ្ឌិតចំនួន ២០នាក់ បានទទួលការបន្ធូរបន្ថយទោស និងលើកលែងទោស ក្នុងឱកាសបុណ្យជាតិឆ្នាំ២០២៥។
- បានអនុវត្តកម្មវិធីបង្វែរ (Diversion) ដោយរួមមាន៖ រៀបចំរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព ១៨៤ករណី, ចូលរួមសវនាការ ៨៩៩ករណី, បង្វែរ ៤៦ករណី និងអនុវត្តវិធានការផ្សេងក្រៅឃុំខ្លួន ៤៩ករណី និងសមាហរណកម្ម ១ករណី និងបិទករណីដោយជោគជ័យ ១៤ករណី។

### ២.២. លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

- មណ្ឌលរដ្ឋ ឯកជន និងអង្គការចំនួន ១៩កន្លែង បានផ្តល់សេវាបន្សាប ព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដោយគ្រឿងញៀនចំនួន ១៩,៤២៨នាក់ (ស្រី ១,១៦៧នាក់) កើនឡើង ៤៣% ធៀបផែនការ។
- បានសមាហរណកម្មជនរងគ្រោះចំនួន ១៩,៣២២នាក់ (កើនឡើង ៧៩%) ខណៈអ្នកកំពុងសម្រាកព្យាបាលនៅសល់ ៨,៧៨៨នាក់។
- បានបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនរងគ្រោះចំនួន ១,៥២៥នាក់ (កើនឡើង ៥៣%) ក្នុងនោះអនុវត្តនៅមជ្ឈមណ្ឌលជាតិ និងមណ្ឌលកណ្តាលស្ទឹង។

### ២.៣. លើកកម្ពស់សុខុមាលភាពជនមានពិការភាព

- ជនមានពិការភាពកំពុងបម្រើការងារនៅស្ថាប័នរដ្ឋមាន ៧,៥០២នាក់ និងវិស័យឯកជន ៦,៩០៥នាក់ ដែលបង្ហាញពីកំណើនគួរឱ្យកត់សម្គាល់។
- បានបណ្តុះបណ្តាលវិជ្ជាជីវៈជនមានពិការភាព (ជំនាន់ទី២៥ និង២៦) លើជំនាញផ្សេងៗ ដោយសម្រេចបាន ៦៧% នៃផែនការ។
- កីឡាករ-កីឡាការិនីមានពិការភាពចូលរួមព្រឹត្តិការណ៍កីឡាចំនួន ១,១៨៩នាក់ និងចូលរួមកម្មវិធីសង្គមផ្សេងៗ ៣៩០នាក់។
- បានពង្រឹងការចូលរួមក្នុងការអភិវឌ្ឍសហគមន៍ប្រកបដោយបរិយាបន្ន (២៧៨នាក់) និងសម្របសម្រួលសេវាយុត្តិធម៌ ៨ករណី។
- អគារដែលមានភាពងាយស្រួលសម្រាប់ជនមានពិការភាពមានចំនួន ៥១៥អគារ និងមាននីតិបុគ្គល ៥១៥ បានចុះបញ្ជិកា និងទទួលវិញ្ញាបនបត្រ។
- បានផ្តល់បណ្ណពិការភាពចំនួន ១៣,៨៩៣នាក់និងអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងបញ្ជិកា។
- បានរៀបចំសន្និសីទថ្នាក់ជាតិ និងកម្មវិធីលើកកម្ពស់សមត្ថភាព និងការយល់ដឹង រួមទាំងការប្រឡងចម្រៀងជនមានពិការភាព។

## ២.៤. លើកកម្ពស់ការតាមដានការអនុវត្តសិទ្ធិជនពិការ

- បានបញ្ជូនរបាយការណ៍ដំបូងអនុវត្តអនុសញ្ញាសិទ្ធិជនពិការ ទៅអង្គការសហប្រជាជាតិ និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ (សម្រេចបានប្រហែល ៨៥%)។
- បានផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ (២០២៤-២០២៨) ដល់អ្នកពាក់ព័ន្ធ ៣,៤៨៧នាក់ និងបណ្តុះបណ្តាលលើហេដ្ឋារចនាសម្ព័ន្ធងាយស្រួល ៥៧០នាក់។
- បានលើកកម្ពស់ការយល់ដឹងតាមរយៈទិវាជាតិ និងអន្តរជាតិ (អ្នកចូលរួម ៤,៧០០នាក់) និងបណ្តុះបណ្តាលអ្នកពាក់ព័ន្ធ ២៩៧នាក់។
- បានចូលរួមសន្និសីទអន្តរជាតិ និងរៀបចំកម្មវិធីលើកទឹកចិត្តយុវជនពិការ។

## ២.៥. កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច

- បានផ្តល់ទីតាំងហាត់ការដល់និស្សិតជំនាញសង្គមកិច្ចវិទ្យា សង្គមវិទ្យា និងគាំពារសង្គម នៅស្ថាប័នចំនួន ៦ សម្រេចបាន ៦០% នៃផែនការឆ្នាំ២០២៥។
- ស្ថាប័ន អង្គការដៃគូ វិស័យឯកជន និងសប្បុរសជនចំនួន ៥១ បានចូលរួមបរិច្ចាគធនធានសម្រាប់ការងារសង្គម សម្រេចបាន ១០២% នៃផែនការឆ្នាំ២០២៥។ ជាមួយគ្នានេះ មូលនិធិសង្គមកិច្ចបានប្រមូលថវិកាបរិច្ចាគសរុប ២៤,០៣១,០០០រៀល សម្រាប់គាំទ្រមន្ទីរពេទ្យគន្ធបុប្ផា និងប្រគល់ថវិកាបន្ថែមចំនួន ៧៨,៨៨៨,៨៨៨ រៀល និង២៨៨.៨៨ដុល្លារអាមេរិក ដល់មូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងយុទ្ធនាការ «១ម៉ឺននាក់ ១ម៉ឺនរៀល»។
- បានរៀបចំពិធីអបអរសាទរទិវាជាតិសង្គមកិច្ចលើកទី១ និងទិវាសង្គមកិច្ចពិភពលោកលើកទី១៨ ឆ្នាំ២០២៥ ក្រោមប្រធានបទ «ពង្រឹងសាមគ្គីភាពអន្តរជំនាន់ដើម្បីធានាបានសុខុមាលភាពយូរអង្វែង» ដោយមានអ្នកចូលរួម ៣០០នាក់ សម្រេចបាន ១០០%។
- បានពិនិត្យ និងកែសម្រួលសេចក្តីព្រាងទី២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈវិជ្ជាជីវៈសង្គមកិច្ច។
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌វិជ្ជាជីវៈសង្គមកិច្ច ការថែទាំជំនួសកុមារ និងផែនការអចិន្ត្រៃយ៍ (ស៊ុំកូនអន្តរប្រទេស) ជូនមន្ត្រី និងអ្នកពាក់ព័ន្ធចំនួន ៥០នាក់ សម្រេចបាន ១០០% នៃផែនការឆ្នាំ២០២៥។

## ២.៦.លើកកម្ពស់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាព

- បានដាក់ហិបវិភាគទានសប្បុរសធម៌របស់មូលនិធិជនពិការចំនួន ៦៧៤ហិប នៅតាមរាជធានី-ខេត្ត និងប្រមូលថវិកាបាន ១៧៦,៩៧១,១៣៦ រៀល សម្រេចបាន ៩៦% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ១១% ធៀបនឹងឆ្នាំ២០២៤។
- បានទទួលប្រាក់ពិន័យអន្តរការណ៍ពីក្រសួង ស្ថាប័ន និងនីតិបុគ្គលដែលមិនបានជ្រើសរើសជនមានពិការភាពចូលបម្រើការងារ ចំនួន ១,៤៥៣,៧១០,២៨៦ រៀល សម្រេចបាន ១១២% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ៣៧% ធៀបនឹងឆ្នាំ២០២៤។
- បានផ្តល់អំណោយសប្បុរសធម៌ជូនជនមានពិការភាពក្រីក្រចំនួន ១,៤៥៣នាក់ សម្រេចបាន ១៣១% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ៥៦% ធៀបនឹងឆ្នាំ២០២៤។
- បានសាងសង់ផ្ទះជូនជនមានពិការភាពក្រីក្រនៅតាមសហគមន៍ចំនួន ១២ខ្នង។
- បានផ្តល់សេវាស្តារលទ្ធភាពពលកម្មគ្រប់ប្រភេទជូនជនមានពិការភាពសរុប ៩០,៦៧៥នាក់ រួមមានសេវាស្តារកាយសម្បទាចំនួន ៤៨,៣៣៥នាក់ និងសេវាស្តារវេជ្ជសាស្ត្រចំនួន ៤២,៣៤០នាក់។

### ២.៦.១.ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា

- ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលដៃគូ ក្រសួង ស.អ.យ. តាមរយៈមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងរោងជាងចំនួន ១៥កន្លែង បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាពសរុប ៣១,១១០នាក់ សម្រេចបាន ១១១% នៃផែនការឆ្នាំ២០២៥ ប៉ុន្តែថយចុះ ៤% ធៀបនឹងឆ្នាំ២០២៤។
- ជនមានពិការភាពដែលមកទទួលសេវា ទទួលបានសេវាដោយឥតគិតថ្លៃ ព្រមទាំងការឧបត្ថម្ភថ្លៃអាហារ និងថ្លៃធ្វើដំណើរ។
- បានផ្តល់អវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយចំនួន ១១,៥១០គ្រឿង/រាយ និងរទេះរុញចំនួន ១,៥៣៣គ្រឿង។
- បានជួសជុលអវយវៈសិប្បនិម្មិត រណប និងឧបករណ៍ជំនួយរាងកាយចំនួន ១៥,៧០២គ្រឿង/រាយ។
- បានផ្តល់សេវាព្យាបាលដោយចលនាជូន ១៤,០២៨នាក់ ស្មើនឹង ១០៨,៥៧២ដង និងព្យាបាលអ្នកជំងឺរបួសខួរឆ្អឹងខ្នង ១៥៦នាក់។
- បានផ្តល់សេវាស្តារលទ្ធភាពពលកម្មពីចម្ងាយ (Open Tele-Rehab) ជូនជនមានពិការភាពចំនួន ៥០៣នាក់។
- បានផ្តល់កន្លែងស្នាក់នៅក្នុងមជ្ឈមណ្ឌលជូនជនមានពិការភាព ៤,៨១៥នាក់ និងអ្នកកំដរ ១,២៩២នាក់។
- បានឧបត្ថម្ភថ្លៃអាហារដល់ជនមានពិការភាព ១៤,៦៦៩នាក់ (៤៩,៣៧២ដង) សម្រេចបាន ៩១% និងឧបត្ថម្ភថ្លៃធ្វើដំណើរ ១៥,២៩៧នាក់ (១៨,១៣៨ដង) សម្រេចបាន ៨៧% នៃផែនការឆ្នាំ២០២៥។

### ២.៦.២. សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ

- បានពិនិត្យ ព្យាបាល និងវះកាត់ជនមានពិការភាពសរុប ៤២,៣៤០នាក់ (កើនឡើង ២១%)។

### ២.៦.៣. សេវាស្តារនៅសហគមន៍

- បានផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមសហគមន៍ជូនជនមានពិការភាពចំនួន ១៦,៣២២នាក់ សម្រេចបាន ១៦៣% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ៩% ធៀបនឹងឆ្នាំ២០២៤។
- បានផលិតគ្រោងអវយវៈសិប្បនិម្មិត រណប ឧបករណ៍ជំនួយរាងកាយ និងរទេះរុញជូនជនមានពិការភាពចំនួន ១៤,១៣៩នាក់ សម្រេចបាន ៧៨% នៃផែនការឆ្នាំ២០២៥ ប៉ុន្តែថយចុះ ៣៦% ធៀបនឹងឆ្នាំ២០២៤។
- ជនមានពិការភាពចំនួន ១១,៩៥៣នាក់ បានទទួលសេវាជួសជុលចល័ត។
- បានផ្តល់រទេះរុញចំនួន ៥១៤គ្រឿង ឈើច្រត់ ៣,៦១៧រាយ និងស្បែកជើងខ្ពស់-ទាប ១៤២គូ។
- បានបញ្ជូនជនមានពិការភាពចំនួន ៤,២៧២នាក់ ទៅកាន់អង្គការ ឬអ្នកផ្តល់សេវាពាក់ព័ន្ធផ្សេងៗ។
- បានចុះសួរសុខទុក្ខអ្នកជំងឺក្នុងសហគមន៍ចំនួន ៩៧នាក់។

## កម្មវិធីទី៣៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម

### ៣.១.ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់

- កម្មវិធីជាតិជំនួយសង្គមផ្នែកបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស បានគាំទ្រយុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យចំនួន ១៧,៧៧៩នាក់ ដោយចំណាយថវិកា ៣៣,២១០,៤៣៨,០០០រៀល (ប្រមាណ ៨.៣លានដុល្លារអាម៉េរិក) សម្រេចបាន ៨៩% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ២២% ធៀបនឹងឆ្នាំ២០២៤។ ក្នុងនោះ យុវជនមានពិការភាពទទួលបានការបណ្តុះបណ្តាលចំនួន ៨១៥នាក់ សម្រេចបាន ១៧២% នៃផែនការ។

- កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ បានចុះបញ្ជីគ្រួសារគោលចំនួន ៧២៥,៤៣៤គ្រួសារ សម្រេចបាន ១០៧% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ១៦% ធៀបនឹងឆ្នាំ២០២៤។ អ្នកទទួលផលរួមមាន ជនចាស់ជរា ៤៣៩,៤៩២នាក់ ជនមានពិការភាព ៥៥,៥៥៩នាក់ អ្នកផ្ទុកមេរោគ/ជំងឺអេដស៍ ៦,០៣១នាក់ សិស្សានុសិស្ស ៥៦៧,១៧៤នាក់ ស្ត្រីមានផ្ទៃពោះ ៤៤,៤០៤នាក់ និងកុមារអាយុក្រោម២ឆ្នាំ ១៤,៥០៧នាក់។
- កម្មវិធីស្តារជីវភាពសម្រាប់ការផ្លាស់ប្តូរលំនៅឋាននៅក្រុងរុនតាឯកតេជោសែន និងឃុំពាក់ស្នែង ខេត្តសៀមរាប បានគាំទ្រគ្រួសារចំនួន ៩,៨៥៣គ្រួសារ (សមាជិក ៤៣,៧៨១នាក់) ដោយចំណាយថវិកាសរុប ៣៣,៣១៧,០១២,០០០រៀល (ប្រមាណ ៨.៣លានដុល្លារអាមេរិក)។
- រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះជាជនជាប់ឃុំចំនួន ៦៥នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន ៨៨នាក់ ដោយចំណាយថវិកា ៤១,៦៤០,០០០រៀល (ប្រមាណ ១០,៤១០ដុល្លារអាមេរិក)។
- បានរៀបចំ និងប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រមូលនិធិជាតិជំនួយសង្គម ឆ្នាំ២០២៤-២០២៨។

## ៣.២.ការបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

- បានរៀបចំបែបបទទទួលស្គាល់មន្ត្រីរាជការចូលនិវត្តន៍ និងផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយរបបសន្តិសុខសង្គមជូន ៣,២៥២នាក់ និងអ្នកនៅក្នុងបន្ទុក ២,៧០៦នាក់ ព្រមទាំងផ្ទេរការគ្រប់គ្រងទៅរាជធានី-ខេត្ត។
- បានចេញប្រកាសលុបសពនិវត្តជនចំនួន ១,៨១៣នាក់ និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ១១៩នាក់។
- និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុកសរុប ១០៥,០៦១នាក់ កំពុងទទួលប្រាក់របបសន្តិសុខសង្គម ដោយចំណាយថវិកាសរុប ៦២៧,៨៤៤,៧៩១,៨៦៤រៀល (ប្រមាណ ១៥៧លានដុល្លារអាមេរិក) សម្រេចបាន ៩៣% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ២% ធៀបនឹងឆ្នាំ២០២៤។
- ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់ ៨៤៥,០០០រៀលក្នុងមួយខែ ចាប់ពីឆ្នាំ២០២៥។
- បានបើកផ្តល់របបសន្តិសុខសង្គមជូនសពមន្ត្រីរាជការស៊ីវិលចំនួន ១,៧៩២សព ដោយចំណាយថវិកាសរុប ១៨,៥០៣,១៣៩,០៦៤រៀល (ប្រមាណ ៤.៦លានដុល្លារអាមេរិក)។

## ៣.៣.ការបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ

- បានទទួលការផ្ទេរអតីតយុទ្ធជនពីក្រសួងមហាផ្ទៃចំនួន ២,៥០៦នាក់ និងក្រសួងការពារជាតិចំនួន ៣,២៩៦នាក់។
- បានលុបឈ្មោះនិវត្តជន និងផ្តល់ប្រាក់ធានារ៉ាប់រងសង្គមជូន ១,២៤១នាក់ ព្រមទាំងលុបឈ្មោះជនបាត់បង់សមត្ថភាពការងារ ២នាក់។
- បានបញ្ចូលបន្ទុកអតីតយុទ្ធជន និងជនបាត់បង់សមត្ថភាពការងារចំនួន ១៤៦នាក់ និងផ្ទេរអតីតយុទ្ធជនតាមសាខារាជធានី-ខេត្តចំនួន ១៧៨នាក់។
- បានផ្តល់ប្រាក់ឧបត្ថម្ភលើកដំបូងជូនជនពិការចំនួន ៥៦០នាក់ និងលុបឈ្មោះជនពិការ/ជនពលីសរុបចំនួន ៩៥៦នាក់។
- បានផ្តល់ប្រាក់របបសន្តិសុខសង្គមជូនអតីតយុទ្ធជន និងគ្រួសារសរុប ២៧៩,២១៧នាក់ ដោយចំណាយថវិកា ១,០១៦,៥៦៥,៧០៦,៨៨៧រៀល (ប្រមាណ ២៥៤លានដុល្លារអាមេរិក) សម្រេចបាន ១០០% នៃផែនការឆ្នាំ២០២៥ និងកើនឡើង ៤% ធៀបនឹងឆ្នាំ២០២៤។
- ប្រាក់សោធនអប្បបរមាសម្រាប់អតីតយុទ្ធជនត្រូវបានដំឡើងស្មើនឹងអតីតមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០២៥។
- បានបើកផ្តល់របបសន្តិសុខសង្គមជូនសពអតីតយុទ្ធជនចំនួន ២,៣៥៩សព ដោយចំណាយថវិកាសរុប ៣៣,៥៨៤,៩២៧,៧៥០រៀល (ប្រមាណ ៨.៤លានដុល្លារអាមេរិក)។

# កម្មវិធីទី៤៖ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច

## ៤.១. លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច

### ៤.១.១.ការងាររដ្ឋបាល និងបុគ្គលិក

- ក្រសួងមានបុគ្គលិកសរុប ២,៩១៧នាក់ ក្នុងនោះស្ត្រី ១,២៤៤នាក់ រួមមានមន្ត្រីរាជការក្នុងក្របខ័ណ្ឌ ២,០០១នាក់ មន្ត្រីជាប់កិច្ចសន្យា ៥៩៨នាក់ និងបុគ្គលិកជាប់កិច្ចសន្យា ៣១៨នាក់។
- នៅទីស្តីការក្រសួង មានមន្ត្រី និងបុគ្គលិកសរុប ២,០៨៥នាក់ ខណៈមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត មានមន្ត្រីសរុប ៨៣២នាក់។
- បានបើកប្រាក់បៀវត្សជូនមន្ត្រីរាជការចំនួន ១,៧៤៩នាក់ សម្រេចបាន ៩៧% នៃផែនការឆ្នាំ២០២៥។
- មន្ត្រីរាជការចំនួន ៣០៩នាក់ ទទួលបានការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស សម្រេចបាន ១២៩% នៃផែនការ។
- បានដំឡើងថ្នាក់ និងឋានន្តរស័ក្តិជូនមន្ត្រីរាជការចំនួន ៦០៩នាក់ សម្រេចបាន ១៣១% នៃផែនការឆ្នាំ២០២៥។
- មន្ត្រីរាជការចំនួន ៣៣៧នាក់ ទទួលបានការលើកទឹកចិត្ត រួមមានគ្រឿងឥស្សរិយយស ២៤០នាក់ និងបណ្ណសរសើរ ១១៥នាក់ សម្រេចបាន ៨៤% នៃផែនការ។
- បានរៀបចំពិធីបុណ្យជាតិ និងអន្តរជាតិចំនួន ២០ពិធី សម្រេចបាន ៩៥% នៃផែនការឆ្នាំ២០២៥។

### ១.២.ការងារផែនការ ស្ថិតិ និងសរុប

- បានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ស.អ.យ. ឆ្នាំ២០២៤-២០២៨ ព្រមទាំងរៀបចំមេតាទិន្នន័យសូចនាករ ផែនការសកម្មភាពឆ្នាំ២០២៥ និងគម្រោងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (២០២៦-២០២៨) ចំនួន ៧គម្រោង សម្រេចបាន ១០០% នៃផែនការ។
- បានរៀបចំរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងរបាយការណ៍វឌ្ឍនភាពនានា រួមទាំងរបាយការណ៍សមិទ្ធផល ២ឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងធាតុចូលសម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សម្រេចបាន ១០០%។
- បានកែលម្អផែនការ និងរបាយការណ៍របស់មន្ទីរ ស.អ.យ. រាជធានី-ខេត្ត តាមរយៈការចុះត្រួតពិនិត្យ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីទាំង ២៥រាជធានី-ខេត្ត សម្រេចបាន ១៥០% នៃផែនការ។
- បានបង្កើត និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានកិច្ចការពារកុមារ (CPIMS) តាមរយៈការបណ្តុះបណ្តាលបញ្ចូល និងប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធ ព្រមទាំងអភិវឌ្ឍផ្ទាំងទិន្នន័យជាប្រចាំ។
- បានធ្វើបច្ចុប្បន្នភាពរបាយការណ៍ពាក់កណ្តាលអាណត្តិនៃគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០។
- បានផ្សព្វផ្សាយលទ្ធផល និងសកម្មភាពការងាររបស់ក្រសួងតាមរយៈសារព័ត៌មាន គេហទំព័រ និងទំព័រ Facebook។

### ១.៣.ការងារគ្រប់គ្រងថវិកា និងសម្ភារ

- បានផ្តល់សេវាគាំទ្រអង្គភាពចំណុះក្រសួងអនុវត្តភារកិច្ចរបស់ខ្លួនចំនួន ៣៣អង្គភាព សម្រេចបាន ១០០% ធៀបជាមួយផែនការសកម្មភាពឆ្នាំ២០២៥ និងរៀបចំកិច្ចប្រជុំ ផ្ទៃក្នុងពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច ចំនួន ៥៤លើក កើនឡើង ៥៤% ធៀបជាមួយផែនការសកម្មភាពឆ្នាំ២០២៥
- ថ្នាក់ដឹកនាំបានបំពេញបេសកកម្មក្នុងអាណត្តិកិច្ចរបស់ក្រសួងចំនួន ៧២៤លើក កើនឡើង ៦០% ធៀបជាមួយផែនការសកម្មភាពឆ្នាំ២០២៥
- ស្ថានភាពថវិកាចំណាយក្នុងឆ្នាំ២០២៥ របស់រដ្ឋបាលទីស្តីការក្រសួងអនុវត្តបានចំនួន ៩២,៩២% និងរដ្ឋបាលមន្ទីរ ស.អ.យ.រាជធានី-ខេត្ត អនុវត្តបានចំនួន ៩២,២៦% ធៀបទៅនឹងផែនការថវិកាប្រចាំឆ្នាំ២០២៥

- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ «ថវិកាសមិទ្ធកម្ម» តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំ បញ្ជីសារពើភ័ណ្ឌកើន-ថយប្រចាំឆ្នាំរបស់អង្គភាពថវិកាក្រោមឱវាទក្រសួង ការបើកផ្តល់ទាន់ពេលវេលា និងចុះបញ្ជីបណ្ណកម្មសិទ្ធិអចលនទ្រព្យចំនួន ៦បណ្ណ។

### ១.៤.ការងារសហប្រតិបត្តិការ

**១. កិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល (NGOs)**

- ក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយសមាគម និងអង្គការចំនួន ៦៩ (លើសផែនការ ៦% និងកើនឡើង ២៣% ធៀបនឹងឆ្នាំ២០២៤)។
- មានអង្គការចំនួន ១៦៩ កំពុងមានសុពលភាពកិច្ចព្រមព្រៀង (ក្នុងស្រុក ៧៨ និងបរទេស ៩១) ក្នុងទំហំថវិកាសរុបជាង ២០០ លានដុល្លារ។
- បានផ្តល់លិខិតគាំទ្រចំនួន ២៨ ករណី (កើនឡើង ៦៥% ធៀបនឹងឆ្នាំមុន) ព្រមទាំងជួយសម្រួលទិដ្ឋាការបុគ្គលិកបរទេស ការនាំចូលសម្ភារៈ និងការធ្វើស្លាកលេខយានយន្តអង្គការ។

**២. កិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំបន់ (អាស៊ាន)**

- សម្រេចបាន ១០០% តាមផែនការ ក្នុងការរៀបចំឯកសារគតិយុត្តចំនួន ៤ និងបានផ្តល់ធាតុចូលលើការងារសុខុមាលភាពសង្គមចំនួន ១០០ ឯកសារ (ក្នុងនោះ ៣៦ ជាឯកសារសំខាន់)។
- ឯកឧត្តមរដ្ឋមន្ត្រីបានដឹកនាំប្រតិភូទៅចក្រភពអង់គ្លេស ដើម្បីសិក្សាពីប្រព័ន្ធថែទាំកុមារ។

**៣. ទំនាក់ទំនងទ្វេភាគី និងរបាយការណ៍វឌ្ឍនភាព**

- បានផ្តល់ធាតុចូល និងរបាយការណ៍វឌ្ឍនភាពចំនួន ២០ ឯកសារ សម្រាប់កិច្ចសហប្រតិបត្តិការជាមួយប្រទេសជាមិត្ត (ដូចជា ដាណឺម៉ាក) និងសម្រាប់ត្រៀមរៀបចំកិច្ចប្រជុំកំពូលពិភពលោកលើកទី២ ស្តីពីការអភិវឌ្ឍសង្គម។

**សរុបមក** សកម្មភាពរបស់ក្រសួងក្នុងឆ្នាំ ២០២៥ នេះមានសន្ទុះកើនឡើងខ្លាំង ជាពិសេសការកៀរគរថវិកាពីដៃគូអភិវឌ្ឍន៍ និងការពង្រឹងទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងអន្តរជាតិ។

### ១.៥.ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

**១. ការងារសវនកម្មផ្ទៃក្នុង**

- បានចុះធ្វើសវនកម្មនៅមន្ទីរ ស.អ.យ. ចំនួន ១៣ រាជធានី-ខេត្ត ក្នុងគោលបំណង ដើម្បីពង្រឹងការគ្រប់គ្រងចំណាយថវិកា និងទ្រព្យសម្បត្តិរដ្ឋ ឱ្យមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការផ្តល់សេវា។ ជាលទ្ធផល សម្រេចបាន ៨៧% នៃផែនការឆ្នាំ២០២៥ (ទាបជាងឆ្នាំ២០២៤ ចំនួន ៩មន្ទីរ)។

**២. ការងារអធិការកិច្ច**

- បានចុះធ្វើអធិការកិច្ចនៅមន្ទីរចំនួន ១៤ រាជធានី-ខេត្ត គោលបំណង ដើម្បីពង្រឹងរបៀបរបបការងារ វិន័យមន្ត្រី ការគ្រប់គ្រងវត្តមាន និងការរៀបចំឯកសាររដ្ឋបាល-ថវិកា។ សម្រេចបាន ១០៨% នៃផែនការ (កើនឡើងខ្លាំងរហូតដល់ ១០មន្ទីរ ធៀបនឹងឆ្នាំ២០២៤)។
- ការដោះស្រាយពាក្យបណ្តឹង ជាលទ្ធផល បានដោះស្រាយបញ្ចប់សព្វគ្រប់នូវ ពាក្យបណ្តឹងអនាមិក ១ករណី របស់និវត្តជន ៥នាក់ នៅស្រុកកំរៀង ខេត្តបាត់ដំបង ដោយផ្អែកលើគោលការណ៍យុត្តិធម៌ និងភាពត្រឹមត្រូវ។
- ការងារអធិការកិច្ចមានការកើនឡើងគួរឱ្យកត់សម្គាល់ (២៥០%) ដែលបង្ហាញពីការយកចិត្តទុកដាក់ខ្ពស់លើវិន័យ និងរបៀបរបបការងារ ខណៈដែលការងារសវនកម្មមានការថយចុះបន្តិចបន្តួចធៀបនឹងឆ្នាំមុន។

### ១.៦.ការងារគោលនយោបាយសង្គមកិច្ច

**១. ការអភិវឌ្ឍគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត**

- បានរៀបចំសេចក្តីព្រាងដំបូងនៃ «គោលនយោបាយជាតិស្តីពីសង្គមកិច្ច» និងដាក់ឱ្យប្រើប្រាស់សៀវភៅស្តង់ដារគុណភាពជាតិសម្រាប់សេវាសង្គមកិច្ច។
- បានតាក់តែង និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តសរុបចំនួន ២៧ ច្បាប់(ថ្មី ៤ និងកែសម្រួល ២៣) សម្រេចបាន ១០០% តាមផែនការ។
- រៀបចំផែនការជាតិស្តីពីការទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ (២០២៥-២០៣០)។

**២. បរិវត្តកម្មឌីជីថល និងទិន្នន័យ (Digital Transformation)**

- ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា និងប្រព័ន្ធមជ្ឈិមទិន្នន័យគ្រប់មុខសញ្ញា (សម្រេចបាន ១០០%)។
- កំពុងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលសង្គមកិច្ច (សម្រេចបាន ៨០%) និងសិក្ខាសាលាផ្សព្វផ្សាយដល់មន្ត្រី។

**៣. ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រី**

- បានរៀបចំសិក្ខាសាលាជាច្រើនដល់មន្ត្រីថ្នាក់ជាតិ និងក្រោមជាតិ សរុបជាង ៦៥០ នាក់ លើប្រធានបទដូចជា៖ គោលនយោបាយសង្គម, ការពិនិត្យតាមដាន និងវាយតម្លៃ, និងការគ្រប់គ្រងបណ្ណសារ។
- សកម្មភាពបណ្តុះបណ្តាលភាគច្រើនសម្រេចបានលើសផែនការ (ចន្លោះពី ១៣៧% ដល់ ២៩៧%)។

**៤. ការកែទម្រង់រដ្ឋបាល និងវិមជ្ឈការ (Decentralization)**

- អនុវត្តអភិក្រម «ពង្រឹងជាជាងពង្រីក» តាមរយៈការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួងឡើងវិញ។
- ចុះពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលរាជធានី-ខេត្ត ចំនួន ១០ មន្ទីរ និងមណ្ឌលថែទាំកុមាររបស់រដ្ឋចំនួន ៥ ខេត្ត។

**៥. កិច្ចសហការអន្តរស្ថាប័ន និងការឆ្លើយតបនឹងបរិស្ថាន**

- ជំរុញឱ្យស្ថាប័នចំនួន ២៨ ដាក់បញ្ចូលស្តង់ដារគុណភាពសេវាសង្គមកិច្ចទៅក្នុងផែនការរបស់ខ្លួន។
- រៀបចំវិធានការ និងសូចនាករគន្លឹះដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ដំណាក់កាលទី ៣)។
- សរុបជារួម ក្រសួងសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់លើសផែនការឆ្នាំ ២០២៥ ស្ទើរគ្រប់ផ្នែក ជាពិសេសលើការងារបណ្តុះបណ្តាល និងការរៀបចំបទដ្ឋានគតិយុត្ត សំដៅពង្រឹងប្រព័ន្ធសង្គមកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព និងទំនើបកម្ម។

## ២.អភិវឌ្ឍធនធានមនុស្សវិស័យសង្គមកិច្ច

ក្នុងឆ្នាំ២០២៥ វិទ្យាស្ថានជាតិសង្គមកិច្ច បាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មឧបករណ៍សិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេស សរុបចំនួន ៨៦០នាក់ ក្នុងនោះនិស្សិតបានចុះឈ្មោះរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ ចំនួន ២២៧នាក់។

**១. ការបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា**

- មាននិស្សិតចំនួន ៦៣៩ នាក់ កំពុងសិក្សាលើជំនាញសំខាន់ៗ ដូចជា សង្គមកិច្ច, កិច្ចគាំពារសង្គម, វិស្វកម្មឧបករណ៍សិប្បនិម្មិត និងរដ្ឋបាលសាធារណៈ។ **ចំនួននេះកើនឡើង ៣៩% ធៀបនឹងឆ្នាំ២០២៤។**
- ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ មាននិស្សិតថ្មីចំនួន ៣២២ នាក់ (លើសផែនការ ២៩% និងកើនឡើង ៤២% ធៀបនឹងឆ្នាំមុន)។

២.លទ្ធផលនៃការបញ្ចប់ការសិក្សា

- ថ្នាក់បរិញ្ញាបត្រៈ និស្សិតបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ៧០ នាក់។
- ថ្នាក់វិញ្ញាបនបត្រៈ សិក្ខាកាមបញ្ចប់វគ្គបណ្តុះបណ្តាលខ្លីៗចំនួន ៧៣ នាក់។

លទ្ធផលទាំងពីរនេះសម្រេចបាន ១០០% តាមផែនការដែលបានកំណត់។

៣.ការពង្រឹងសមត្ថភាពមន្ត្រីរាជការ

- បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសង្គមកិច្ចចំនួន ៣ វគ្គ ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីថ្នាក់ជាតិសរុប ចំនួន ២៧១ នាក់ (សម្រេចបាន ៤៥% នៃផែនការឆ្នាំ២០២៥)។
- **សរុបជារួម** វិទ្យាស្ថានជាតិសង្គមកិច្ចបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតធនធានមនុស្សលើវិស័យសង្គមកិច្ច ដោយមានកំណើននិស្សិតគួរឱ្យកត់សម្គាល់ និងបន្តពង្រឹងសមត្ថភាពមន្ត្រីជំនាញដែលមានស្រាប់ឱ្យកាន់តែមានវិជ្ជាជីវៈខ្ពស់។

## ៤. ថវិកាក្រសួង ស.អ.យ. ប្រចាំឆ្នាំ ២០២៦

### ៤.១.ធនធានថវិកាឆ្នាំ ២០២៦

ក្រសួងបានទទួលថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលក្នុងឆ្នាំ២០២៦ នេះ មានចំនួន **២ ៥៧៤ ៣៩៨ លានរៀល** ធៀបនឹងថវិកាឆ្នាំ២០២៥ កើនឡើង ៨,៨% និងថវិកាផ្ទាល់[២] ចំនួន **២ ៤៧៦,៩ លានរៀល** ដើម្បីអនុវត្តកម្មវិធីចំនួន៤ រួមមាន ទី១.លើកកម្ពស់សេវាសង្គមកិច្ច ទី២.ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ ទី៣.ការអនុវត្តកម្មវិធីគាំពារសង្គម និង ទី៤.សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច។ថវិកាកម្មវិធីទាំង៤នេះបានរួមបញ្ចូល ថវិការបស់អង្គភាពចំណុះទីស្តីការក្រសួង និងមន្ទីរស.អ.យ.រាជធានី-ខេត្តទាំង២៥។

តារាងទី២. ក្រាហ្វិកថវិការក្រសួងតាមកម្មវិធី

(ឯកតា៖លានរៀល)




[២] *ថវិកាផ្ទាល់ ជាថវិកាដែលទទួលបានពីការដាក់ហិប និងកម្មវិធីសប្បុរសធម៌នានា*

តារាងទី៣. គម្រោងថវិកាចំណាយតាមកម្មវិធី និងអនុកម្មវិធី

ឯកតាពាន់រៀល

| សរុបថវិការួម | ថវិកាឆ្នាំ២០២៦ | |
|---|---|---|
| | ថវិការដ្ឋ | ហិ. ផ្ទាល់ |
| | 2,574,398.0 | 2,476.9 |
| **កម្មវិធីទី១៖ លើកកម្ពស់សេវាសង្គមកិច្ច** | 35,625.5 | |
| អនុកម្មវិធីទី១.១៖លើកកម្ពស់សេវាគាំពារមនុស្សចាស់និងអតីតយុទ្ធជន | 4,768.0 | |
| អនុកម្មវិធីទី១.២៖លើកកម្ពស់សេវាកិច្ចការពារកុមារ | 1,135.5 | |
| អនុកម្មវិធីទី១.៣៖លើកកម្ពស់កិច្ចការគ្រួសារ | 221.2 | |
| អនុកម្មវិធីទី១.៤៖លើកកម្ពស់សេវាគាំពារជនរងគ្រោះ | 13,989.2 | |
| អនុកម្មវិធីទី១.៥៖សេវាគាំទ្រកាលើកកម្ពស់សេវាសង្គមកិច្ច រាជធានី ខេត្ត | 15,511.6 | |
| **កម្មវិធីទី២៖ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ** | 34,335.3 | |
| អនុកម្មវិធីទី២.១៖លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន | 1,562.0 | |
| អនុកម្មវិធីទី២.២៖លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន | 5,312.0 | |
| អនុកម្មវិធីទី២.៣៖លើកកម្ពស់សុខុមាលភាពជនមានពិការភាព | 796.5 | |
| អនុកម្មវិធីទី២.៤៖កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច | 259.3 | |
| អនុកម្មវិធីទី២.៥៖លើកម្ពស់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព | 16,237.6 | 2,476.9 |
| អនុកម្មវិធីទី២.៦៖សេវាគាំទ្រការគ្រប់គ្រងសេវាស្តារជនរងគ្រោះ រាជធានី ខេត្ត | 10,167.9 | |
| **កម្មវិធីទី៣៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម (មជជ)** | 2,443,837.1 | |
| អនុកម្មវិធីទី៣.១៖លើកកម្ពស់សេវាបើកផ្តល់តាវកាលិកនិងរបបគោលនយោបាយ | 2,414,158.8 | |
| អនុកម្មវិធីទី៣.២៖លើកកម្ពស់សមត្ថភាពស្ថាប័ន និងការផ្សព្វផ្សាយ | 1,026.5 | |
| អនុកម្មវិធីទី៣.៣៖រៀបចំគោលនយោបាយ និងកិច្ចការនីតិកម្មជំនួយសង្គម | 378.0 | |
| អនុកម្មវិធីទី៣.៤៖សេវាគាំទ្រកិច្ចដំណើរការអនុវត្តកម្មវិធីគាំពារសង្គម | 28,273.8 | |
| អនុកម្មវិធីទី៣.៥៖សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម រាជធានី ខេត្ត | | |
| **កម្មវិធីទី៤៖ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច** | 60,600.1 | |
| អនុកម្មវិធីទី៤.១៖លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច | 31,438.9 | |

ឯកតាពាន់រៀល

| សរុបថវិការួម | ថវិកាឆ្នាំ២០២៦ | |
|---|---|---|
| | ថវិការដ្ឋ | ហិ. ផ្ទាល់ |
| | 2,574,398.0 | 2,476.9 |
| អនុកម្មវិធីទី៤.២៖អភិវឌ្ឍន៍ធនធានមនុស្សវិស័យសង្គមកិច្ច (NISA) | 475.2 | |
| អនុកម្មវិធីទី៤.៣៖លើកកម្ពស់ការអភិវឌ្ឍគោលនយោបាយសង្គមកិច្ច (អគ្គ.គ/ន សង្គមកិច្ច) | 518.5 | |
| អនុកម្មវិធីទី៤.៤៖លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ (CNCC) | 215.0 | |
| អនុកម្មវិធីទី៤.៥៖លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិជនពិការ (DAC) | 285.0 | |
| អនុកម្មវិធីទី៤.៦ ៖សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ចរាជធានី-ខេត្ត | 27,667.5 | |

## តារាងទី៤.ក្រាហ្វិកថវិកាកម្មវិធីទី១ លើកកម្ពស់សេវាសង្គមកិច្ច




រូបភាពទី១






## តារាងទី៥.ក្រាហ្វិកថវិកាកម្មវិធីទី២ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ




### រូបភាពទី២





តារាងទី៦.ក្រាហ្វិកថវិកាកម្មវិធីទី៣ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម (មជជ)




រូបភាពទី៣









## តារាងទី៧.ក្រាហ្វិកថវិកាកម្មវិធីទី៤ សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ច




## រូបភាពទី៤








## ៥.សេចក្តីសន្និដ្ឋាន

ថវិកាឆ្នាំ២០២៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ.) នឹងត្រូវប្រើប្រាស់ជាឧបករណ៍គោលនយោបាយដ៏សំខាន់ ក្នុងការគាំទ្រ និងជំរុញការអនុវត្ត**«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១»** របស់រាជរដ្ឋាភិបាល ក៏ដូចជាការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០២៤-២០២៨ ឱ្យសម្រេចបានតាមគោលដៅដែលបានកំណត់។

តាមរយៈកញ្ចប់ថវិកានេះ ក្រសួង ស.អ.យ. នឹងបន្តពង្រឹងការផ្តល់សេវាសាធារណៈជូនដល់ក្រុមអ្នកទទួលផលរបស់ខ្លួន រួមមាន ជនងាយរងគ្រោះ កុមារ ជនពិការ មនុស្សចាស់ អតីតយុទ្ធជន និវត្តជន និងអនីតិជនទំនាស់នឹងច្បាប់ ដោយធានាបាននូវប្រសិទ្ធភាព ប្រសិទ្ធផល សមធម៌ និងសក្តិសិទ្ធភាព ស្របតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

ជាមួយគ្នានេះ ការរៀបចំផែនការយុទ្ធសាស្ត្រ និងការបែងចែកថវិកាឆ្នាំ២០២៦ នឹងបន្តផ្តល់អាទិភាពលើការលើកកម្ពស់គុណភាព និងការពង្រីកវិសាលភាពសេវាសាធារណៈ ស្របតាមឯកសារគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តជាធរមាន ដូចជា៖ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ, ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, និងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន។

លើសពីនេះ ការអនុវត្តថវិកានឹងត្រូវផ្សារភ្ជាប់ជាមួយគោលនយោបាយ និងផែនការជាតិពាក់ព័ន្ធ រួមមាន៖ គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ឆ្នាំ២០១៧-២០៣០, គោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៧-២០៣០, គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ, គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារឆ្នាំ២០១៩-២០២៩, ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧, កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដំណាក់កាលទី២ ឆ្នាំ២០២១-២០៣០ ព្រមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងផែនការសកម្មភាពពាក់ព័ន្ធផ្សេងៗ។

សរុបមក ថវិកាឆ្នាំ២០២៦ នឹងក្លាយជាយន្តការហិរញ្ញវត្ថុដ៏សំខាន់សម្រាប់ក្រសួង ស.អ.យ. ក្នុងការបន្តអនុវត្តកំណែទម្រង់វិស័យសង្គមកិច្ច ពង្រឹងប្រព័ន្ធគាំពារសង្គម និងលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។